# ពូជស្រូវធន់ប្រកាន់រដូវ សម្រាប់ផលិតកម្មស្រូវ និងនាំអង្ករចេញ




### ក. ពូជស្រូវរាំងជ័យ :

- ជាពូជស្រូវធ្ងន់ ទិន្នផលខ្ពស់ មានគុណភាពអង្ករល្អប្រសើរ មានភាពភ្លឺថ្លា និងបាយទន់ល្មម និងឆ្ងាញ់ពិសារ ។
- ពូជស្រូវប្រកាន់រដូវមធ្យម ចាប់ចេញផ្កានៅពាក់កណ្តាល ខែវិច្ឆិកា និងច្រូតកាត់នៅពាក់កណ្តាល ខែធ្នូ និងដើម ខែមករា អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។ ពូជនេះមានកំពស់ដើមពី ១០៥ ស.ម - ១៦៨ ស.ម
- ចំនួនដើមបែកពី ៥ ទៅ ១០ដើមក្នុង១គុម្ព អាចមានទៅដល់១៥-២០ដើមក្នុង១គុម្ព។
- ប្រវែងកួរពី១៦ ទៅ ៣០ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៨៦ ទៅ ៣៣៤ គ្រាប់ ។
- ជាប្រភេទពូជធន់ទ្រាំមធ្យម ទៅនឹងការលិចទឹកជំនន់
- ទិន្នផលពី ៣.៥ តោន ទៅ ៥.៥តោន ក្នុង១ហិកតា។

### ខ. ពូជស្រូវខា៤ :

- ជាពូជស្រូវធ្ងន់ មានទិន្នផលខ្ពស់ គុណភាពអង្ករល្អប្រសើរ មានភាពភ្លឺថ្លា បាយទន់ និងឆ្ងាញ់ពិសារ
- ជាប្រភេទពូជស្រូវធ្ងន់ប្រកាន់រដូវ ចាប់ចេញផ្កានៅពាក់កណ្តាលខែវិច្ឆិកា និងច្រូតកាត់នៅពាក់កណ្តាល ខែធ្នូ អាស្រ័យតាមអាកាសធាតុ និងពេលវេលាដាំដុះ។
- កម្ពស់ដើមពី ១៣២ ស.ម - ១៧៣ ស.ម ចំនួនដើមបែកពី ៦ - ១០ ដើមក្នុង១គុម្ព។ អាចដល់២០ ទៅ ២៥ ដើមក្នុង១គុម្ព ។
- ប្រវែងកួរមានពី២០ ទៅ ៣០ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៦០ ទៅ ១៩០ គ្រាប់។
- ជាប្រភេទពូជធន់ទៅនឹងភាពរាំងស្ងួត
- ទិន្នផលពី ២.៥ តោន ទៅ ៥.០ តោនក្នុង១ហិកតា។

### គ. ពូជស្រូវខា៦ :

- ជាពូជស្រូវធ្ងន់ ពូជនេះមានទិន្នផលខ្ពស់ មានគុណភាពអង្ករល្អ មានភាពភ្លឺថ្លា និងបាយទន់ឆ្ងាញ់ពិសារ។
- ប្រកាន់រដូវ ចាប់ចេញផ្កាពីថ្ងៃ៩ - ១៦ ខែវិច្ឆិកា និងច្រូតកាត់ នៅពាក់កណ្តាលខែធ្នូ និងអាចដល់ចុងខែធ្នូ អាស្រ័យតាមអាកាសធាតុ និង ពេលវេលាដាំដុះ។
- កំពស់ដើមពី ១២៩ ស.ម - ១៧៧ ស.ម ចំនួនដើមបែកពី ៧ ទៅ ៩ ដើមក្នុង១គុម្ព អាចដល់ ១៥ ទៅ ២០ដើមក្នុង១គុម្ព។
- ប្រវែងកួរមានពី២១ ទៅ ២៥ ស.ម និងចំនួនគ្រាប់ក្នុង១កួរមានពី១៥៥ ទៅ ១៨៨ គ្រាប់។
- ទិន្នផលពី ៣.៥ តោន ទៅ ៥.៨ តោនក្នុង១ហិកតា។

### បច្ចេកទេសដាំដុះសម្រាប់ពូជទាំង ៣ :

សំណាប ប្រើពូជស្រូវសុទ្ធ និងមានគុណភាពល្អ ដោយប្រើពូជពី ២០ ទៅ ៤០ គីឡូក្រាមសម្រាប់ស្ទូង១ហិកតា ។ សាបគ្រាប់ស្រូវ១គីឡូក្រាម លើផ្ទៃដីថ្នាល១០ម៉ែត្រការ៉េ ។ អាយុកាលពី១៥ ទៅ ២០ថ្ងៃ ត្រូវដកយកទៅសន្ទូង ដោយដកភ្លាមស្ទូងភ្លាមនៅក្នុងថ្ងៃតែមួយ។ ស្រែសន្ទូងត្រូវភ្ជួរឲ្យបាន ២ ទៅ ៣ដង និងរាស់កៀរដីឲ្យបានរាបស្មើល្អ និងប្រើជីកំប៉ុស្ត ឬ ជីលាមកគោពុកផុយចំនួន៥ តោន ឬ ២០ រទេះគោ និងអាចប្រើជី ដេ អា ប៉េ ចំនួន ៥០គ.ក្រ ទៅ ១០០គ.ក្រ ទ្រាប់បាត តាមប្រភេទដី ។ ស្ទូង ១ ដើម ទៅ ៣ ដើមក្នុង១គុម្ព ជាជួរ ឬ មុំចង្រានដោយស្ទូងចំនួន ២០ គុម្ព ទៅ ២៥ គុម្ពក្នុង១ម៉ែត្រការ៉េ។

### ការប្រមូលផល និងទុកដាក់គ្រាប់ស្រូវ :

ត្រូវច្រូតកាត់នៅក្រោយពេលស្រូវចេញផ្កាស្រុះរយៈពេល ៣០ ទៅ ៣៥ថ្ងៃ ឬ ពេលដែលគ្រាប់ស្រូវទុំប្រមាណ ៨៥ ភាគរយ ត្រូវបោកបែនភ្លាមក្រោយពីច្រូតកាត់ និងហាលគ្រាប់ស្រូវ ២-៣ ថ្ងៃ ឲ្យសំណើមគ្រាប់មាន ១៤ ភាគរយ ឬគ្រាប់ស្រូវស្ងួតល្អមានសភាពរឹង តែមិនស្រួយបាក់នៅពេលខាំ។ ត្រូវទុកដាក់គ្រាប់ស្រូវក្នុងបាវក្រចៅ ។

សហការផលិតដោយ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ CAVAC